# 4

# អ្វីដែលខ្ញុំបានឃើញ, បានដឹងនិង បានឮនៅជនបទ

នៅពេលដែលពួកយើងចាកចេញពីផ្លូវ យើងសង្កេតឃើញថា ពួកគេមានវិធានការណ៍ការពារហ្មត់ចត់ណាស់។ មានមនុស្សយាមល្បាតតាមផ្លូវជាលំដាប់ទៀងទាត់ មិនសូវឃ្លាតពីគ្នាប៉ុន្មានទេ ហើយពាក្យសង្ងាត់ត្រូវគេបញ្ជូនទៅគ្នាជាទៀងទាត់តាមបណ្ដោយផ្លូវដែលយើងធ្វើដំណើរដោយស្ងៀមស្ងាត់ក្រោមពន្លឺព្រះច័ន្ទ។ មិនដល់កន្លះម៉ោងផង ពួកយើងបានមកដល់ទិសដៅ។ យើងខ្ញុំត្រូវបានគេបានអញ្ជើញឲ្យឡើងលើផ្ទះមួយ ដែលទំនងជាធំជាងគេនៅក្នុងភូមិ។ ពេលឡើងដល់លើផ្ទះ យើងខ្ញុំបានឃើញ តា-ម៉ុក អង្គុយចាំយើងជាស្រេច។ គាត់ស្លៀកខោខ្ញីពណ៌ខ្មៅ អាវដៃខ្ញីពណ៌ខ្មៅចំហទ្រូវ នៅដៃមានកាន់ក្រមាមួយ។

ដោយពោលហៅម្ចាស់ផ្ទះឲ្យមកជាមួយគាត់ៗ ក៏បានអញ្ជើញយើងខ្ញុំឲ្យអង្គុយលើបន្ទះក្ដារមួយជុំវិញចង្កៀងប្រេងកាតធ្វើអំពីកំប៉ុងដឹកញ្ចាស់មួយ។ ថ្វីបើចង្កៀងប្រេងកាតជះពន្លឺព្រៀងៗក៏ពិតមែន តែយើងអាចមើលឃើញភ្នែកដ៏ជ្រៅមុតថ្លារបស់គាត់ ដែលលេចចេញពីមុខ ដែលមានដុះរោមស្រម៉ូវរបស់គាត់។

ពិធីស្វាគមន៍ត្រូវបញ្ចប់ដោយសង្ខេប។ គាត់បានសាកសួរអំពីដំណើររបស់យើងខ្ញុំ ហើយបានណែនាំយើងខ្ញុំមិនឲ្យដើរហើរចេញពីផ្ទះ លើកលែងតែពេលយប់ ដើម្បីបត់ជើង និង លប់លាងខ្លួន ដែលពួកយើងត្រូវធ្វើដោយស្ងប់ស្ងាត់។ គាត់បានហាមប្រាមយ៉ាងតឹងតែងដល់ម្ចាស់ផ្ទះមិននរណាឡើងចុះលើផ្ទះជាដាច់ខាត។ បន្ទាប់មក គាត់ក៏ចាកចេញទៅ ដោយប្រាប់យើងខ្ញុំ កុំឲ្យព្រួយបារម្ភណ៍ពីសុវត្ថិភាពខ្លួនអី។

នៅថ្ងៃបន្តបន្ទាប់ យើងគ្មានសង្កេតឃើញអ្វីកើតឡើងខុសប្រក្រតីឡើយ។ ជីវភាពនៅតាមជនបទ ហាក់ប្រព្រឹត្តិទៅដដែលៗ ដូចដែលធ្លាប់មានតាំងពីរាប់សតវត្សមកហើយ នៅតាមភូមិដ្ឋាននានារបស់ខ្មែរ។ ម្យ៉ាងទៀត ខ្ញុំក៏ដូចជា ហ៊ុយ-យុន ដែរ ហាក់មានចិត្តសង្រោកសង្រែង ស្រងេះស្រងោចជាពន់ពេក យើងគ្មានចិត្តឯណា ទៅចាប់អារម្មណ៍លើរឿងផ្សេងឡើយ។ ពួកយើង គិតតែពីគេងសន្ធឹងសន្ធៃលើក្ដារ ផ្ដោតចក្ខុសម្លក់សម្លឹងពិតាន។ ហ៊ុយ-យុន នៅមានពាក្យកំប្លែងសើចលេងខ្លះៗដែរ។ គាត់អង្គុយប្របម៉ាត់បង្អួច ច្រៀងរហ៊ឹមនូវបទចំរៀងដ៏ពេញនិយមមួយ។ ឯខ្ញុំៗមានចិត្តសោកស្ដាយជាប់ ព្រោះមិនបានលាអ្នកមានគុណ មុនពេលចាកចេញមក។ ម្ដាយខ្ញុំតែងរំឭកខ្ញុំជានិច្ចថា“ពងមាន់កុំចង់ជល់នឹងថ្ម” ខ្ញុំមានចិត្តសោកស្ដាយដោយមិនបានស្ដាប់គាត់។ ឥឡូវលទ្ធផលវាយ៉ាងនេះឯង... ខ្ញុំមានបំណងចង់ប្រាប់គាត់ថា ខ្ញុំមិនដែលល្មើសនឹងគាត់ទេ ហើយតែងមានចិត្តស្មោះត្រង់ចំពោះខ្លួនខ្ញុំ ចំពោះរូបគាត់ និងចំពោះជាតិ ជានិច្ច។

©រក្សាសិទ្ធិគ្រប់យ៉ាង

http://www.amekhmer.org

មានសំណួរជាច្រើនអន្ទោលចាកស្រេះក្នុងខួរក្បាលរបស់ខ្ញុំ ។ តើការសែតជាភាសាបារាំង ដូចយ៉ាងការសែត“ឧបសៃវ៉ាទ័រ” អាចគេចាត់ទុកថា ជាវិទ្ធង្សនាម្ដេចកើត បើសារនាការរបស់វាក៏រិតត្រឹមតែចំពោះជនដែលមានកំរិតវប្បធ៌មមួយចំនួន? តើគេអាចចាត់ទុកថាជាអំពើក្បត់ដែរឬ បើគ្រាន់តែមានបំណងចង់ឲ្យជាតិមានការរីកចំរើនសេដ្ឋកិច្ចនិងសង្គម ហើយមានកិត្តិយស និងមានសេចក្ដីថ្លៃថ្នូរ។ នៅពេលដែលខ្ញុំសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់ខ្ញុំ ខ្ញុំចិញ្ចឹមចិត្តថានឹងផ្ដួចផ្ដើមគំនិតធ្វើការកែទម្រង់សេដ្ឋកិច្ចនិងសង្គម ដើម្បីឲ្យមានការប្ដូរផ្ដាស់មកពីខាងលើមកវិញ។ នៅពេលដែលខ្ញុំបានដឹងថា កិច្ចការកែទម្រង់ ត្រូវសម្ដេចប្រគល់ជូនលោក សឺន-សាន តាមដែលខ្ញុំបានស្នើទៅសម្ដេច ខ្ញុំគិតថា ប្រទេសយើងនឹងអាចធ្វើដំណើរឆ្ពោះទៅមុខតាមទិសដៅដែលខ្ញុំបានសរសេរនៅចុងបញ្ចប់នៃនិក្ខេបបទរបស់ខ្ញុំ។ គួរបញ្ជាក់ថា កិច្ចការទាំងនេះទាមទារឲ្យមានការប្រយុទ្ធតស៊ូយ៉ាងដាច់អហំង្ការប្រឆាំងនឹងអំពើរពុករលួយ ដែលជាជម្រើសនយោបាយមួយដ៏ពិបាក។ តែនេះជាតម្លៃដែលត្រូវបង់ខាត ប្រសិនជាយើងចង់ជៀសវាងការបង្ហូរឈាមគ្នាក្នុងសង្គមផង និង ក៏ដើម្បីទប់ស្កាត់នឹងសកម្មភាពឃុបឃិតបំផ្លាញនយោបាយអព្យាក្រិតរបស់សម្ដេច ដែលដឹកនាំដោយពួក លន់-ណុល ហើយទោះបីដោយចេតនាក្ដី ឬអចេតនាក្ដី អំពើទាំងនេះ បានអូសទាញប្រទេសខ្មែរឲ្យធ្លាក់ក្នុងភ្លើងសង្គ្រាមវៀតណាម។

នៅពេល ដែលខ្ញុំកំពុងតែរំឭកឡើងវិញនូវគ្រប់ឧប្បត្តិហេតុទាំងឡាយនៃមាគ៌ាជីវិតរបស់ខ្ញុំ នារយៈពេលប្រាំបីឆ្នាំចុងក្រោយនេះ ខ្ញុំក៏បានឮពាក្យប្លែកៗជាច្រើនដែលចេញពីការសន្ទនាប្រចាំថ្ងៃរបស់អ្នកភូមិ ដូចជាពាក្យ “ឯករាជ្យ” “ម្ចាស់ការ” “ត្រូវតែហ៊ានតស៊ូដោយឯករាជ្យ” ។ល។ ពេលខ្លះយើងបានឮការសន្ទនាអ៊ូរអែរអំពីបទពិសោធន៍នៃការតស៊ូកន្លងមក ដែលគេត្រូវចាំទុកជាមេរៀនពីកិច្ចព្រមព្រៀងនៅហ្សឺណែវ ។ល។

ពាក្យពេជន៍និងការសន្ទនាបែបនេះ យើងដែលមិននឹកស្មានថាអាចឮនៅទីនេះទេ ដូច្នេះវារិតតែធ្វើឲ្យ យើងមានការចាប់អារម្មណ៍ចង់ដឹងថែមទៀត។ តាមរយៈការសន្ទនានេះហើយ ដែលយើងបានដឹងថាពីវត្តមាននៃសមាគមកសិករផ្សេងៗ ដូចជាមូលនិធិសម្រាប់ជួយឧបត្ថម្ភអ្នកខ្វះស្រូវអង្ករបរិភោគនៅរដូវក្ដួររាស់, សមាគមសម្រាប់ទិញថ្នាំពេទ្យឬប្រេងសាំង ដែលនឹងលក់ចែកគ្នាក្នុងតម្លៃសមរម្យ, ក្រុមប្រវាស់ដៃ ។ល។

គឺដោយមូលហេតុនេះហើយ ដែលយើងបានស្នាក់នៅក្នុងភូមិដ្ឋាននោះ ដោយមិនសូវជាអផ្សុកប៉ុន្មានទេ។ តាម៉ុកតែងឆ្លៀតមកលេងនឹងយើងម្ដងម្កាល ដោយនាំមកជាមួយនូវប័ត្រមនោគម

បួនខែនេះ ប្រហែលជាពេលវេលាគេទុកឲ្យយើងទម្លាប់រស់នៅតាមជនបទ។ ដោយការយកចិត្តទុកដាក់របស់គេ ពួកយើងអាចទិញអ្វីៗដែលយើងចង់បាននៅផ្សារអង្គតាសោម។

ក្រោយបន្តិចមក តាម៉ុកបានប្រាប់យើងថា នឹងឲ្យគេនាំយើងចូលទៅក្នុងកាន់តែជ្រៅ តែគាត់មិនប្រាប់ថានឹងនាំយើងទៅទីណាទេ គាត់គ្រាន់តែប្រាប់ថា សំខាន់បំផុតគឺ កុំឲ្យតែមានប៉ូលិសចាប់យើង។ ដូច្នេះ ចាំបាច់យើងមិនត្រូវស្នាក់នៅមួយកន្លែងយូរទេ។

ប៉ុន្តែ មួយរយៈមក ហ៊ុយ-យុន ក៏មានចិត្តធុញទ្រាន់និងរបៀបរស់នៅធក់កន្តៀតនិងអសកម្មបែបនេះ ហើយគាត់បានបញ្ចេញអាការៈធុញថប់របស់គាត់ ។ ថ្ងៃមួយគាត់ភ្ញាក់ពីព្រឹក រៀបចំខោអាវ ក្ឱយមុងរបស់គាត់ដាក់ក្នុងសម្ពាយ។ ដោយការងឿងឆ្ងល់ ខ្ញុំក៏សម្រេចចិត្តសួរនាំគាត់។ គាត់ក៏ឆ្លើយដោយកំបុតកំបុយថា“ខ្ញុំទៅផ្ទះវិញ”។ មកដល់ដំណាក់ការនេះហើយ ខ្ញុំគិតថា វាជាអំពើលីលាពេកហើយ។ ដូច្នេះ ខ្ញុំក៏ព្យាយាមពន្យល់គាត់ថា“បើបងត្រឡប់ទៅវិញ វាជារឿងមួយគ្រោះថ្នាក់បំផុតដល់ខ្លួនបងផ្ទាល់ ក៏ដូចជាដល់អ្នកដែលបានជួយលាក់បំពួនយើងដែរ”។ គាត់ក៏ឆ្លើយមកខ្ញុំវិញថា “ខ្ញុំមិនមែនកូនក្មេងទេ ការរស់នៅបែបនេះ មិនមែនជាជីវិតទេ”។ ខ្ញុំមិនដឹងជារកពាក្យអ្វីឆ្លើយតបទៅគាត់វិញទៀត ក៏សុំឲ្យគាត់ឲ្យរង់ចាំជួបតាម៉ុកសិន។ ពេលព្រលប់ តាម៉ុកក៏មកជួបពិគ្រោះគ្នា ហើយក៏សម្រេចចិត្តឲ្យ ហ៊ុយ-យុន ត្រឡប់ទៅភូមិទងវិញ។ ឯខ្ញុំក៏បន្តដំណើរតទៅទៀតតែម្នាក់ឯង។

ការដែលខ្ញុំចេះតែធ្វើដំណើរពីភូមិមួយទៅភូមិមួយ ខ្ញុំក៏បានដឹងពីខ្សែរយៈចាត់តាំងសម្ងាត់របស់បក្សកុម្មុយនីសកម្ពុជា ដែលលាតសន្ធឹងតាំងពីក្បែរផ្លូវជាតិលេខ៣ ជិតអង្គតាសោម រហូតដល់ជើងភ្នំឱរ៉ាល់។ ភូមិដ្ឋានទាំងនោះហាក់នៅដាច់ៗពីគ្នានៅឡើយទេ តែដំណើររបស់ខ្ញុំ វាមិនខុសពីដំណាក់ប្រេងដែលដានលើក្រដាសទេ។

ខ្ញុំនៅចាំអនុស្សាវរីយ៍ពីភូមិមួយយ៉ាងច្បាស់។ មើលពីក្រៅទៅ ភូមិនោះមិនមានអ្វីខុសប្លែកពីភូមិដ្ឋានដទៃទេ មិននឹកស្មានថា ជាខ្សែរយៈចាត់តាំងមួយរបស់បក្សកុម្មុយនីសកម្ពុជាសោះ។ គឺជាភូមិមួយតូចនៅក្បែរព្រៃ មានតែខ្ទម៤ នៅក្រោមម្លប់ដើមស្វាយ២-៣ ។ ខ្ទមដែលគេទុកសម្រាប់ខ្ញុំគឺជាជង្រុកស្រូវមួយ គេធ្វើយ៉ាងនេះ ដើម្បីកុំឲ្យគេចាប់អារម្មណ៍។ ខ្ញុំនៅទីនោះដេកសន្ធឹងសន្ធៃលើក្តារ ដែលរៀបបន្តជាប់គ្នាដោយគ្មានបោះដែកគោលផ្ជាប់គ្នាទេ។ គ្រាន់តែកំរើកខ្លួនបន្តិច ក្តារទាំងពីរដែលលូតហួសផុតខ្ទមនោះនឹងប៉ះឡើង។ ក្តារទាំងនេះ អាចធ្វើឲ្យអ្នក ដែលដើរកាត់តាមនោះ មានការងឿងឆ្ងល់មិនខាន ជាសំណាងល្អទីនោះមិនសូវ មានមនុស្សធ្វើដំណើរកាត់ទេ តែបើមានវិញក៏យើងមិនដែលដឹងជាមុនដែរ។

នៅពេលថ្ងៃក្នុងភូមិមានភាពស្ងាត់ជ្រងំ។ ព្រឹកៗឡើងមានតែក្មេងស្រីម្នាក់អាយុប្រហែល១២ឆ្នាំតែងមកបុកស្រូវអង្ករ ទុកប្អូនប្រុសវាលេងពពៀកដីខ្លួនទនលគក។ ម្តងៗពេលអង្រែភ្លាត អង្ករខ្ទាតប្រាវមកក្រៅ នាំឲ្យមាន់ទាដែលរកស៊ីក្បែរនោះរត់ប្រញ៉ាយដណ្តើមគ្នាចឹកស៊ី។ មើលទៅ

អង្រែនោះ វាហាក់ដូចជាធួន់និងធំខ្ពស់កម្លាំងក្មេងស្រីនោះជាពន់ពេក។ ឪពុកម្តាយក្មេងៗនោះ បានចេញទៅស្រែរហូតដល់ល្ងាចបានត្រលប់មកវិញ។ ឯអ្នកជិតខាងទាំងប៉ុន្មាន បានទាំកូនចៅគេចេញទៅព្រៃស្វែងរកបោចផ្កៅអស់ទៅហើយ។ ៣ ទៅ ៤ថ្ងៃ ទើបគេយកទៅលក់នៅផ្សារតាឡាត់ដែលស្ថិតនៅជិតត្រពាំងក្រឡឹង តាមបណ្តោយផ្លូវជាតិលេខ៤។ ឯដំណើរថ្មើរជើងទៅមកពីភូមិនោះទៅផ្សារតាឡាត់ ត្រូវចំណាយពេលអស់មួយថ្ងៃ។

ក្មួយស្រីតែងលើកម្ហូមអាហារមកឲ្យខ្ញុំរាល់តែថ្ងៃជាទៀតទាត់។ មានបាយនិងញាំសំបកឪឡឹកជាមួយជីរនាងវងនិងអំបិល។ ពេលខ្លះក៏មានស្រីឡៀតខ្លះទៅ ពេលខ្លះទៀតក៏មានសម្ល្រត្រយល្ពៅនិងសម្លជំឡូងឈាមមាន់ ...

អ្វីៗហាក់ប្រព្រឹត្តិទៅដដែលៗ គ្មានអ្វីប្លែកសោះ។ ស្រាប់តែថ្ងៃមួយមានយាយម្នាក់កាន់ចេកមួយស្និតឡើងជណ្តើរខ្ទមរបស់ខ្ញុំ ដោយប្រើដៃម្ខាងវាវស្ទាបរកកាំជណ្តើរ នៅពេលដែលខ្ញុំស្ទុះទៅជួយគ្រា ទទួលគាត់នៅមាត់ទ្វារ គាត់ក៏ចាប់អង្អែលដៃខ្ញុំ ស្ទាបក្បាលខ្ញុំ ថ្ពាល់ខ្ញុំ ដោយទឹកភ្នែករលីងរលោង ហើយមានវាចាថា “កូនអើយ! សាច់ទន់ល្អក ចុះម្តេចក៏មកទីនេះនឹងគេដែរ”។ ខ្ញុំរំជួលចិត្តជាខ្លាំង ក៏តបទៅវិញថា “មិនអីទេម៉ែ! ម៉ែ មា មីង នៅទីនេះល្អណាស់ ដូច្នេះ មានអ្វីដែលខ្ញុំនៅមិនបានទេ”។

យាយកសិកររូបនេះ បានបង្ហាញនូវមនោសញ្ចេតនាអាណិតអាសូរខ្ញុំ ដោយស្មោះពិតប្រាកដណាស់។ ដោយហាក់មិនបានគិតជាមុនផង គាត់បានសម្តែងឲ្យខ្ញុំយល់ថា ឋានៈសង្គមរបស់ខ្ញុំ “ខ្ពស់ណាស់”។ ទាំងនេះ ធ្វើឲ្យខ្ញុំកាន់តែគិតច្រើនអំពីសង្គមជាតិយើង “អ្នកមាន និង អ្នកក្រ វាខុសគ្នាដល់ម្ល៉ឹង”។

ទាំងនេះជាអ្វីៗដែលខ្ញុំបានឃើញ ឮ និង ទទួលអារម្មណ៍ នៅពេលដែលខ្ញុំជួបប្រទះស្រ័យជាលើទីមួយជាមួយនិងចលនាខ្មែរក្រហម។ គឺវាប្រកបដោយទុក្ខព្រួយផង និង ការរំជួលចិត្តផង។

ក្រៀមក្រំ ឈឺចាប់ ព្រោះប្រហែលជានឹងត្រូវបែកគ្នាជារៀងរហូត ពីម្តាយខ្ញុំ ពីក្រុមគ្រួសារបងប្អូន និង មិត្តភក្តិ ដែលខ្ញុំធ្លាប់ស្គាល់ ធ្លាប់រួមគ្នាគិតពីរឿងជាតិ។

តែម្យ៉ាងមានចិត្តរំភើប ពីព្រោះបានឃើញកម្លាំងជាតិមួយថ្មីកំពុងលេចចេញជារូបរាង ដែលជាកម្លាំងជាតិពិតប្រាកដ ចាក់ឫសនៅក្នុងសន្តានចិត្តរបស់កសិករនៅជើងភ្នំក្រវាញទាំងនេះ នៅក្នុងពេលដែលមានសញ្ញាជាច្រើនបញ្ជាក់ថា ប្រទេសជាតិយើងនឹងត្រូវពើបប្រទះនឹងគ្រោះមហន្តរាយដ៏ធំមួយ។ គំនិតរបស់បក្សកុម្មុយនីសកម្ពុជាយល់ថា កម្លាំងរបស់គេអាចដើរតួដូច

បក្សកុម្មុយនីសបារាំង នៅពេលប្រទេសបារាំងត្រូវពួក ហ្វាស៊ីស អាល្លឺម៉ង់ ឈ្លានពាន ការណ៍នេះធ្វើឲ្យខ្ញុំមានអារម្មណ៍ធូរស្រាលវិញ។

# IV
# Ce que j'ai vu, entendu et ressenti à la campagne

A notre descente de la route, nous avons constaté que les mesures de sécurité étaient minutieuses. Des hommes avaient été placés à espaces réguliers, pas trop éloignés les uns des autres et des mots de passe se soufflaient à un rythme également régulier tout au long du sentier que nous suivions en silence à bicyclette à la lueur des étoiles. Une demi-heure à peine, et nous parvenions à destination . Nous fûmes invités à monter dans une maison, visiblement la plus grande du village. Là Ta Mok nous attendait. Comme tous les paysans du village, il était en culotte noire et en chemise noire à courtes manches déboutonnées, avec un krama tenu à la main. Tout en appelant le propriétaire de la maison à venir avec lui, il nous invita à nous asseoir à même le plancher autour d'une lampe faite d'une vielle boîte de lait remplie de pétrole. La lumière diffuse de la lampe nous permettait tout de même de découvrir les yeux profonds et perçants qui se détachaient de sa face barbue. La cérémonie de bienvenue fut brève. Il s'enquit affablement de notre voyage et nous recommanda de ne jamais sortir de la maison, sauf la nuit pour les besoins et le bain, et de ne pas parler à haute voix. Ses instructions au propriétaire et à toute sa famille étaient strictes : ne laisser (' *Un village appelé Chieng Tong, dans la commune du même nom et dans le district de Samrong Tong (Kampong Speu).*personne monter à la maison. Puis il se retira en nous assurant de notre sécurité.

Les premiers jours, nous n'avons rien remarqué de particulier. La monotonie de la vie rustique semblait continuer à se répéter, comme il en avait été toujours ainsi depuis des siècles dans n'importe quel village de la campagne cambodgienne. D'ailleurs, aussi bien Hou Youn que moi-même, puisque c'est de nous deux qu'il s'agit, étions dans un état de tristesse et de désespoir trop profond pour nous intéresser à ce qui se passait autour de nous. Nous passions ainsi des heures entières à nous étendre sur le plancher, les yeux fixés au toit. Hou Youn trouvait de temps en temps des mots pour rire et parfois, assis à la fenêtre, il fredonnait une des mélodies prisées en ce temps. Quant à moi, le regret d'avoir dû quitter ma mère sans même lui dire un mot d'adieu me poursuivait. Elle n'avait de cesse de me répéter : « l'oeuf ne doit pas chercher à se cogner à un roc », et je regrettais de ne pas l'avoir écoutée. Et maintenant voilà le résultat ! J'aurais bien aimé pouvoir lui expliquer qu'à aucun moment, je ne lui avais désobéi et que j'avais toujours été honnête envers moi-même, envers elle et envers notre pays...

Et une foule de questions ne cessait de me poursuivre. En quoi un journal de langue française comme «l'Observateur » pouvait-il être considéré comme conspirateur ou subversif, alors que son audience était nécessairement limitée à un cercle restreint de gens d'un certain niveau de culture ? Est-ce une conspiration, le fait d'imprimer le souhait de voir le Cambodge parvenir à un certain progrès économique et social et retrouver ainsi sa dignité nationale ? Alors que je préparais ma thèse de fin d'études, je nourrissais l'espoir de voir l'initiative des réformes indispensables pour de tels progrès venir d'en haut1. Et lorsque j'appris que la charge de procéder aux réformes proposées dans le plan que j'avais soumis au Prince chef de l'État était confiée à S.E. Son Sann, la porte me sembla ouverte pour que notre pays puisse avancer dans le sens suggéré en conclusion de ma thèse. Est-il nécessaire d'ajouter que cela impliquait cependant une lutte sans compromis contre la corruption et donc un choix politique assez déchirant. C'était bien le prix à payer si l'on voulait éviter des conflits sociaux sanglants et neutraliser les activités de sape de ceux-là qui, guidés par la cupidité, conspiraient (c'est bien le cas de le dire) avec Lon Nol contre la politique de neutralité et, consciemment ou non, étaient en train de pousser le pays dans le gouffre de la guerre du Vietnam.

©រក្សាសិទ្ធិគ្រប់យ៉ាង

http://www.amekhmer.org

Pendant que je distillais ainsi en silence les péripéties de mon parcours de ces huit années passées, des expressions tout à fait étranges me parvenaient des conversations quotidiennes : «indépendance », «maîtrise», «oser lutter en toute indépendance», etc... Il nous arrivait même parfois d'entendre des discussions animées sur l'expérience de la lutte passée, sur les leçons à tirer des accords de Genève, etc... Ces mots et discussions que nous ne. nous attendions nullement à entendre ici, ne faisaient qu'exciter notre intérêt et notre curiosité. C'est ainsi que, à travers ces conversations, nous décelions peu à peu l'existence d'associations paysannes très variées : fonds d'entraide en paddy pour l'assistance aux nécessiteux pendant la période de soudure, association pour l'achat en commun de médicaments ou de pétrole pour lampes pour en revendre à un prix convenable, équipes d'entraide en vue des prochaines semailles.

*1-Dans l'Histoire, nous avons l'exemple du Japon où l'Empereur et les autres dirigeants du pays n'avaient pas attendu jusqu'à l'explosion d'une révolution, comme cela avait été le cas de la France en 1789.*

Nous passâmes ainsi quatre mois dans le village sans trop nous ennuyer. Ta Mok venait de temps en temps nous voir et nous apporter quelques brochures idéologiques ronéotypées du P.C.K.

Quatre mois dans ce village, c'était peut-être une période d'adaptation qu'on nous avait accordée, car ici, par les bons soins des uns ou des autres, nous pouvions acheter à Ang Ta Som tout ce dont nous avions besoin.

Par la suite Ta Mok vint nous dire qu'on allait nous amener plus profondément à l'intérieur du pays. Il se garda de nous préciser la destination. L'essentiel, nous ditil, était de ne pas nous laisser attraper par la police. Et la prudence conseillait de ne pas rester trop longtemps à la même place.

Mais au bout d'un certain temps dans le nouveau village, Hou Youn commença à s'ennuyer de cette vie confinée et inactive et à manifester son énervement. Un jour, de bon matin, il se mit à ranger ses effets dans son sac à dos. Intrigué, je lui demandai ce qu'il faisait. Il me répondit sèchement: « Je rentre ». Au point où l'on en était, je trouvais que c'était de la folie. J'essayai de le raisonner: « Mais, tu n'imagines pas le danger, pour toimême et pour tous ceux qui nous ont hébergés ? ». Il me rétorqua: « Je ne suis pas un gamin. Et puis, ce n'est pas une vie ici ». A bout d'arguments, je l'implorai d'attendre au moins Ta Mok et de discuter avec lui. Ce dernier arriva dans la soirée, et leur discussion aboutit à un compromis. Le lendemain, Hou Youn fut raccompagné à Cheang Toung. Je continuai donc mon chemin, seul.

J'allais donc de villages en villages, découvrant ainsi tout un réseau du P.C.K. qui se tissait dans la clandestinité depuis les abords de la route n°3 près de Ang-Ta-Som jusqu'au pied du mont Oral. Ces villages étaient encore épars, mais tout indiquait que, lentement mais sûrement, ils feraient tâche d'huile.

Je garde un souvenir particulier de l'un d'eux qui, comme tant d'autres, sans payer de mine, était probablement une des mailles de ce réseau. Adossé à la forêt, il était minuscule, composé de quatre cabanes, nichées à l'ombre de quelques manguiers. Celle qui m'avait été assignée avait servi de grenier à paddy et devait continuer à passer comme tel. Je restais là, la plupart du temps, allongé sur le « plancher » fait de quelques planches rangées l'une à côté de l'autre, sans aucun clou pour les fixer quelque part aux poutres. Un simple geste en faisait remuer les deux bouts qui dépassaient de la cabane. Cela aurait risqué d'intriguer des visiteurs, qui étaient heureusement assez rares, mais qui arrivaient sans jamais s'annoncer.

Le jour, le village était presque désert. Seule une petite fille d'environ 12 ans s'occupait de très bonne heure à pilonner du paddy, laissant son petit frère s'amuser à même le sol, tout nu. Parfois le pilon obliquait et le riz s'éparpillait par terre, à la joie des quelques volailles qui picoraient à côté : pour la petite le pilon était trop lourd et trop haut. Ses deux parents allaient à la rizière, et n'en revenaient qu'à la tombée du soleil. Les voisins allaient dans la forêt d'à côté, avec tous les enfants, chercher des lianes. A peu près tous les 3 ou 4 jours, ils allaient en

vendre au marché de Talat, près de Trâpeang Krâloeung sur la route n°4 à une journée à pied du village.

La petite fille me montait régulièrement les repas quotidiens : riz, écorce de pastèque râpée avec des feuilles de menthe et du sel. Parfois le repas était agrémenté d'un peu de poisson sec ou d'un peu de soupe de légumes, préparée tantôt avec des fleurs et des pousses de potiron, tantôt avec quelques morceaux d'une espèce de tubercule communément appelée « sang de poulet » parce qu'elle donnait à la soupe une couleur rougeâtre.

Les jours se répétaient ainsi monotones, lorsqu'une vieille paysanne monta l'escalier de ma cabane à tâtons, en amenant avec elle une "main" de banane. Comme je me levais pour l'aider à franchir le pas de la porte, elle me tâta les mains, les bras, la tête et les joues, et, les larmes aux yeux, elle me dit: « Mon fils ! Que ta peau est douce! Qu'est-ce qui t'amène ici... ? Pour nous oui, nous ne connaissons que ça, de toute notre vie. Mais toi... ? » Bouleversé, je lui répondis: « Ne t'en fais pas mère ! Puisque toi, les oncles et les tantes, vous êtes si bons, il n'y a pas de raison que je ne puisse pas vivre parmi vous... »

La vieille paysanne, tout en témoignant sa profonde affection à mon égard, m'avait fait savoir, sans s'en rendre compte, que je venais de «très haut », et m'avait donné tout un sujet de réflexion sur la structure de notre société.

Voilà un parfum de ce que j'ai vu, entendu et ressenti lors de mon premier contact avec le mouvement khmer rouge : c'était à la fois triste et revivifiant.

Triste, car la douleur d'être séparé peut-être à jamais de ma mère, de mes frères et soeurs, et l'amertume de voir ruinés mes efforts pour des réformes politiques et économiques du pays, étaient toujours là.

Revivifiant, parce que j'étais en train d'assister à l'émergence d'une force éminemment nationale prenant racines profondément dans le coeur de nos paysans aux pieds de la chaîne des Cardamones et cela, au moment où bien des signes présageaient déjà le malheur qui allait s'abattre sur notre pays. Un vague sentiment que le P.C.K. pourrait éventuellement jouer un rôle semblable à celui du Parti Communiste Français dans la Résistance à l'occupation allemande me réconfortait.

©រក្សាសិទ្ធិគ្រប់យ៉ាង
http://www.amekhmer.org